# 42 이 기계 어떻게 작동하는지 알아요?

## តើដឹងថាម៉ាស៊ីននេះត្រូវដំណើរការដូចម្ដេចទេ?

**학습 안내**
ការណែនាំអំពីមេរៀន

| | |
|---|---|
| □ វត្ថុបំណងមេរៀន | ការពន្យល់ពីវិធីដំណើរការម៉ាស៊ីន, ការរាយការណ៍ការងារ |
| □ វេយ្យាករណ៍ | –는지 알다/모르다, –(으)ㄹ 것 같다 |
| □ ពាក្យថ្មី | ការដំណើរការម៉ាស៊ីន, ការងារវេចខ្ចប់ |
| □ ព័ត៌មាន · វប្បធម៌ | របៀបប្រើប្រាស់ឧបករណ៍និងម៉ាស៊ីនដោយសុវត្ថិភាព |

## 대화 1 ការសន្ទនា ១

Track 130



បារូនិងមីនស៊ូកំពុងតែធ្វើការសន្ទនាគ្នា។ ដំបូងសូមស្ដាប់ការសន្ទនាឲ្យបាន២ដងជាមុនសិន រួចហើយចូរថាតាម។

**민수** 바루 씨, 오늘은 이 기계로 목재 자르는 일을 해야 해요.
បារូ, ថ្ងៃនេះត្រូវធ្វើការកាត់ឈើ ដោយប្រើប្រាស់ម៉ាស៊ីននេះ។

**바 루** 그래요? 민수 씨는 이 기계 어떻게 작동하는지 알아요? 전 이걸 써 본 적이 없어서요.
អញ្ចឹងឬ? តើមីនស៊ូដឹងថាត្រូវដំណើរការម៉ាស៊ីននេះដូចម្ដេចទេ? ពីព្រោះខ្ញុំមិនដែលធ្លាប់ប្រើប្រាស់ម៉ាស៊ីននេះទេ។

**민수** 자, 이렇게 하면 돼요. 먼저 손잡이에 있는 안전 스위치를 누르세요. 그리고 이 전원 스위치를 올리면 기계가 작동하기 시작해요. 이렇게 ……. 자, 한번 해 보세요.
នេះ, ធ្វើយ៉ាងនេះទៅបានហើយ។ ជាដំបូងសូមចុចកុងតាក់សុវត្ថិភាពនៅកន្លែងកាន់។ បន្ទាប់មកលើកកុងតាក់នេះ រួចហើយម៉ាស៊ីននឹងចាប់ផ្ដើមដំណើរការ។ ធ្វើដូច្នេះ.......នេះ, សូមសាកធ្វើម្ដងទៅមើល។

**바 루** 손잡이에 있는 안전 스위치를 누르고 전원 스위치를 올리면 ……. 아, 되네요.
ចុចកុងតាក់សុវត្ថិភាពនៅកន្លែងកាន់ហើយលើកកុងតាក់......
អ៊ំ, បានហើយ។

**민수** 기계가 작동하기 시작하면 손잡이를 위아래로 움직여서 목재를 자르면 돼요.
នៅពេលដែលម៉ាស៊ីនចាប់ផ្ដើមដំណើរការ សូមកំរើកប្រដាប់កាន់ឡើងចុះហើយកាត់ឈើ។

> **이걸** 이것을 = 이걸
> ជាធម្មតានៅពេលនិយាយ ភាគច្រើនគេប្រើប្រាស់‘이걸’។
> · 이걸 사고 싶은데 얼마예요?
> ខ្ញុំចង់ទិញរបស់នេះ តើតម្លៃប៉ុន្មាន?
> · 이걸 다른 걸로 바꾸고 싶어요.
> ខ្ញុំចង់ប្ដូរវាជាមួយរបស់ផ្សេង។

> **–기 시작하다**
> នៅពេលដែលកិរិយាស័ព្ទមកពីមុខ ‘시작하다(ចាប់ផ្ដើម)’ យើងត្រូវប្ដូរទម្រង់កិរិយាស័ព្ទទៅជា ‘V–기’ ជាមុនសិន។
> · 어제부터 한국 회사에 다니기 시작했어요.
> បានចាប់ផ្ដើមធ្វើការនៅក្រុមហ៊ុនកូរ៉េចាប់តាំងពីម្សិលមិញ។
> · 아침부터 비가 내리기 시작했어요.
> ភ្លៀងបានចាប់ផ្ដើមធ្លាក់ចាប់តាំងពីព្រឹក។



តើអ្នកបានស្ដាប់និងថាតាមការសន្ទនារួចហើយមែនដែរឬទេ? អញ្ចឹងសូមឆ្លើយនឹងសំណួរខាងក្រោម។

1. 바루 씨는 오늘 무슨 일을 할 거예요? ថ្ងៃនេះតើបារូនឹងធ្វើការងារអ្វី?
2. 이 기계를 사용할 때 제일 먼저 무엇을 해야 해요? នៅពេលប្រើប្រាស់ម៉ាស៊ីននេះ មុនដំបូងតើត្រូវធ្វើអ្វី?

**정답** 1. 목재 자르는 일을 할 거예요. 2. 안전 스위치를 눌러야 해요.

## 어휘 1 ពាក្យថ្មី ១ | 기계 작동 ការធ្វើឲ្យម៉ាស៊ីនដំណើរការ



តោះ! ទៅមើលទាំងអស់គ្នាថាពាក្យដែលទាក់ទងនឹងការដំណើរការម៉ាស៊ីនមានអ្វីខ្លះ?



작동하다
ដំណើរការ



사용하다/쓰다
ប្រើប្រាស់



누르다
ចុច



올리다
លើក



내리다
ទម្លាក់ចុះ



돌리다
បង្វិល



끼우다
ដាក់
(ដាក់អំពូល...)



꽂다
ដោត



빼다
ដក



걸다
ព្យួរ



적재하다
ផ្ទុក

- 스위치를 위로 **올리면 작동하기** 시작합니다.
  ប្រសិនជាលើកកុងតាក់ទៅលើ នោះវានឹងចាប់ផ្តើមដំណើរការ។
- 불을 켜려면 버튼을 **누르세요.**
  ប្រសិនជាចង់បើកភ្លើងសូមចុចប៊ូតុង។



សូមកុំមើលពាក្យដែលនៅខាងលើ ហើយសាកល្បងឆ្លើយសំណួរ។

1. 그림을 보고 알맞은 말을 연결하세요. សូមមើលរូបភាព បន្ទាប់មកចូរភ្ជាប់ទៅនឹងពាក្យដែលត្រឹមត្រូវ។

① 
② 
③ 
④ 
⑤ 

㉠ 걸다 ㉡ 빼다 ㉢ 꽂다 ㉣ 끼우다 ㉤ 적재하다

정답 ① ㉡ ② ㉣ ③ ㉤ ④ ㉠ ⑤ ㉢

## 문법 1 វេយ្យាករណ៍ ១ | -는지 알다/모르다

G42-1

យើងប្រើប្រាស់ '-는지 알다/모르다' ភ្ជាប់ជាមួយកិរិយាស័ព្ទ ដើម្បីបង្ហាញចំងល់អំពីការពិតនៃប្រយោគនៅខាងមុខ។ ទោះបីជាពាក្យខាងក្រោយនៃប្រយោគមានជើងឬមិនមានយ៉ាងណាក៏ដោយ គឺប្រើប្រាស់ទម្រង់ '-는지 알다/모르다' ទាំងអស់។

- 가: 이 기계를 어떻게 **끄는지 알아요**? តើដឹងថាម៉ាស៊ីននេះបិទដូចម្តេចទេ?
  나: 네, 손잡이를 왼쪽으로 돌리면 돼요. បាទ/ចាស, បង្វិលប្រដាប់កាន់ទៅខាងឆ្វេងទៅជាការស្រេច។
- 가: 이걸 어떻게 **꽂는지 모르겠어요**. មិនដឹងថាត្រូវដោតវាដូចម្តេចនោះទេ។
  나: 이쪽을 잡고 꽂으면 돼요. ចាប់ខាងនេះហើយដោតទៅជាការស្រេច។



តើអ្នកបានយល់អំពីការប្រើប្រាស់ '-는지 알다/모르다' ហើយមែនដែរឬទេ? អញ្ចឹងសូមប្រើប្រាស់កិរិយាស័ព្ទដែលបានរៀបចំទុកនោះ យកមកបញ្ចប់ការសន្ទនា។

2. '-는지 알다/모르다'를 사용해서 대화를 완성하세요.
   សូមប្រើប្រាស់ '-는지 알다/모르다' មកបញ្ចប់ការសន្ទនា។

   1) 가: 이 기계 어떻게 ______________________? [작동하다]
      តើដឹងថាត្រូវដំណើរការម៉ាស៊ីននេះដូចម្តេចទេ?
      나: 네, 스위치를 올리면 돼요. បាទ/ចាស, លើកកុងតាក់ឡើងទៅជាការស្រេច។

   2) 가: 이걸 어디에 꽂는지 알아요? តើដឹងថាត្រូវដោតនៅកន្លែងណាទេ?
      나: 아니요, ______________________. [꽂다]
      អត់ទេ, មិនដឹងថាត្រូវដោតនៅកន្លែងណាទេ។

   3) 가: 이 전구요. 어떻게 ______________________? [끼우다]
      អំពូលភ្លើងនេះ។ មិនដឹងថាត្រូវដាក់វាដូចម្តេចនោះទេ។
      나: 잠깐만요. 제가 해 볼게요. សូមចាំមួយភ្លែត។ ខ្ញុំនឹងសាកធ្វើ។

정답 1) 작동하는지 알아요 2) 어디에 꽂는지 몰라요 3) 끼우는지 알아요



រៀនថែមបន្តិចទៀតតើល្អដែរឬទេ? សូមសាកល្បងប្រើប្រាស់ '-는지 알다/모르다' មកបញ្ចប់ការសន្ទនា។

1) 가: 시내에 어떻게 __________ 알아요? តើដឹងថាត្រូវទៅ ទីរួមខេត្តយ៉ាងណាទេ?
   나: 네, 205번 버스를 타세요. បាទ/ចាស, សូមជិះឡានក្រុងលេខ២០៥។
2) 가: 우체국이 어디에 __________ 알아요? តើដឹងថាប្រៃសណីយ៍មាននៅកន្លែងណាទេ?
   나: 은행 옆에 있어요. មាននៅក្បែរធនាគារ។

정답 1) 가는지 2) 있는지

## 대화 2 ការសន្ទនា ២

Track 131



អ៊ីនឌីខានិងលោកប្រធានកំពុងតែសន្ទនាគ្នា។ ជាដំបូង សូមស្ដាប់ថាតើគេកំពុងតែនិយាយគ្នាអំពីអ្វីឲ្យបាន២ដង រួចហើយចូរថាតាមការសន្ទនា។

**반 장** 오늘 작업은 얼마나 진행됐어요?
ថ្ងៃនេះតើធ្វើការបានប៉ុន្មានហើយ?

**인디카** 오전에는 골판지 자르는 작업을 끝냈고요, 오후부터 접고 붙이는 작업을 하고 있어요. 그러면 6시까지는 주문 받은 상자를 완성할 수 있을 것 같아요.
ពេលព្រឹកបានបញ្ចប់ការងារកាត់ក្រដាសកាតុង។ ហើយចាប់ពីពេលថ្ងៃមកបានកំពុងតែធ្វើការបិទភ្ជាប់គ្នា។ បើអញ្ចឹងដល់ម៉ោង៦ប្រហែលជាអាចរួចរាល់ប្រអប់ដែលបានកុម្ម៉ង់ហើយ។

**반 장** 골판지는 충분해요? 어제 작업 끝난 후에 보니까 얼마 남지 않았던데요.
តើក្រដាសកាតុងគ្រប់គ្រាន់ដែរឬទេ? ម្សិលមិញបន្ទាប់ពីបញ្ចប់ការងារ មើលទៅដូចជាមិននៅសល់ច្រើនប៉ុន្មាននោះទេ។

**인디카** 네, 지난주에 주문한 골판지가 오늘 오후에 도착할 거니까 문제없을 것 같아요.
ចាស, ដោយសារក្រដាសកាតុងដែលបានកុម្ម៉ង់កាលពីអាទិត្យមុន នឹងមកដល់ថ្ងៃនេះ ដូច្នេះប្រហែលជាគ្មានបញ្ហានោះទេ។

**얼마 남지 않다**
មិននៅសល់ប៉ុន្មានទេ។(នៅសល់មិនច្រើន)

- 일이 얼마 남지 않았어요. 곧 끝날 거예요.
  ការងារនៅសល់មិនច្រើននោះទេ។ វានឹងចប់ឆាប់ៗ។
- 한국으로 떠나는 날이 얼마 남지 않았어요.
  ថ្ងៃដែលត្រូវទៅប្រទេសកូរ៉េនៅសល់មិនច្រើនទេ។

**문제없다** គ្មានបញ្ហា

- 상품의 질이 좋아서 판매하는 데는 문제없을 거예요.
  ដោយសារគុណភាពនៃទំនិញល្អ ដូច្នេះវានឹងគ្មានបញ្ហាក្នុងការលក់ចេញនោះទេ។
- 다음 주 출장 준비는 문제없이 잘되고 있습니까?
  តើការត្រៀមសម្រាប់ដំណើរទស្សនៈកិច្ចការងារនៅសប្ដាហ៍ក្រោយគ្មានបញ្ហាទេឬ?



តើអ្នកបានស្ដាប់និងថាតាមការសន្ទនារួចហើយមែនដែររឺទេ?
អញ្ចឹងសូមឆ្លើយនឹងសំណួរខាងក្រោម។

1. 인디카 씨는 오전에 무슨 일을 했어요? តើអ៊ីនឌីខាបានធ្វើអ្វីពេលព្រឹក?
2. 인디카 씨는 골판지를 언제 주문했어요? តើអ៊ីនឌីខាបានកុម្ម៉ង់ក្រដាសកាតុងពេលណា?

**정답** 1. 골판지 자르는 일을 했어요. 2. 지난주에 주문했어요.

## 어휘 2 ពាក្យថ្មី ២ | 포장 작업 ការងារវេចខ្ចប់

តោះ! ទៅមើលទាំងអស់គ្នាថាពាក្យដែលត្រូវការប្រើប្រាស់ក្នុងការងារវេចខ្ចប់មានអ្វីខ្លះ?



재다
វាស់



자르다
កាត់



오리다
កាត់យកចេញ



접다
បត់



붙이다
បិទ



달다
ដាក់, ព្យួរ



조절하다
លៃតម្រូវ ឬសារើ



완성하다
សម្រេច, រួចរាល់



제작하다
ផលិត, បង្កើត



옮기다
ជញ្ជូន ឬរើ

- 상자를 **자른** 후에 **접으세요.**
  សូមកាត់កេស(ប្រអប់)ហើយបត់។
- 상자에 손잡이를 **달면** 완성됩니다.
  ដាក់ដៃកាន់នៅប្រអប់រួចជាការស្រេច។
- 상자를 **옮기는** 일을 하고 있어요.
  កំពុងតែធ្វើការរើប្រអប់ចេញ។

សូមរំលឹកពាក្យដែលបានរៀននៅខាងលើម្តងទៀត បន្ទាប់មកចូរសាកល្បងឆ្លើយសំណួរ។

1. 그림에 맞는 표현을 〈보기〉에서 골라 넣으세요.
   សូមជ្រើសរើសកន្សោមពាក្យពី<ឧទាហរណ៍>យកមកបំពេញឲ្យបានត្រឹមត្រូវទៅនឹងរូបភាព។

 →  →  →  → 

| 1) | 2) | 3) | 4) | 5) |
|---|---|---|---|---|

**보기**　붙이다　자르다　접다　오리다　재다

정답 1) 재다 2) 자르다 3) 오리다 4) 접다 5) 붙이다

## 문법 2 វេយ្យាករណ៍ ២ | -(으)ㄹ 것 같다

G42-2

យើងប្រើប្រាស់ '-(으)ㄹ 것 같다' ភ្ជាប់ជាមួយកិរិយាស័ព្ទឬគុណនាម ដើម្បីទស្សទាយនូវរឿងរ៉ាវឬស្ថានភាពដែលនឹងត្រូវកើតឡើងនៅពេលអនាគត។

- 가: 언제 작업이 **끝날 것 같아요**? តើការងារប្រហែលជាចប់ម៉ោងប៉ុន្មាន?
  나: 6시쯤 **끝날 것 같아요.** ប្រហែលជាចប់ម៉ោង៦ជាង។
- 가: 곧 비가 **올 것 같아요**. ប្រហែលជាភ្លៀងនឹងធ្លាក់ឆាប់ៗនេះ។
  나: 그래요? 우산은 가지고 왔어요? អញ្ចឹងឬ? តើបានយកឆ័ត្រមកជាមួយដែរឬទេ?

### 비교해 보세요 សូមសាកល្បងធ្វើការប្រៀបធៀប

✔ រវាង '-(으)ㄹ 것 같다' និង '-는/(으)ㄴ 것 같다'

យើងប្រើប្រាស់ 'A/V-(으)ㄹ 것 같다' គឺបង្ហាញពីការប៉ាន់ស្មានអំពីអ្វីមួយនាពេលអនាគត, ចំណែកឯ 'V-는 것 같다, A-(으)ㄴ 것 같다' វិញ គឺបង្ហាញពីការប៉ាន់ស្មានអំពីអ្វីមួយដែលស្ថិតនៅក្នុងពេលបច្ចុប្បន្ន។

- 오후에는 비가 **올 것 같아요**. នៅពេលរសៀល ប្រហែលជាធ្លាក់ភ្លៀង។
- 지금 비가 **오는 것 같아요**. ពេលនេះ ដូចជាធ្លាក់ភ្លៀង។



តើអ្នកបានយល់អំពីការប្រើប្រាស់ '-(으)ㄹ 것 같다' ហើយមែនដែររឺទេ? អញ្ចឹងសូមសាកល្បងបញ្ចប់ការសន្ទនាឲ្យបានត្រឹមត្រូវទៅនឹងខ្លឹមសារ។

2. '-(으)ㄹ 것 같다'를 사용해서 대화를 완성하세요.
   សូមប្រើប្រាស់ '-(으)ㄹ 것 같다' មកបញ្ចប់ការសន្ទនា។

1) 가: 언제까지 완성할 수 있을까요? តើអាចនឹងរួចរាល់ត្រឹមពេលណា?
   나: ______________________.
   [2시까지 할 수 있다 អាចដល់ម៉ោង២]

2) 가: 상자 300개를 내일 아침까지 제작할 수 있을까요?
   តើអាចនឹងផលិតកេស៣០០កេស ត្រឹមព្រឹកថ្ងៃស្អែកបានដែរឬទេ?
   나: ______________________.
   [그것은 힘들다 រឿងនោះវាពិបាក]

3) 가: ______________________?
   [자르는 작업을 다 끝낼 수 있다 ការងារកាត់នឹងអាចធ្វើឲ្យរួចរាល់បាន]
   나: 그럼요. 제가 도와줄 테니까 걱정하지 마세요. ប្រាកដហើយ។ ខ្ញុំជាអ្នកជួយ ដូច្នេះសូមកុំបារម្ភ។

4) 가: 바루 씨, 내일 같이 소풍을 가는 게 어때요? បារូ, ថ្ងៃស្អែកទៅធ្វើដំណើរកំសាន្តជាមួយគ្នា, យ៉ាងម៉េចដែរ?
   나: ______________________.
   [날씨가 아주 맑다 អាកាសធាតុពិតជាស្រឡះល្អ]

정답 1) 2시까지 할 수 있을 것 같아요 2) 그것은 힘들 것 같아요 3) 자르는 작업을 다 끝낼 수 있을 것 같아요 4) 날씨가 아주 맑을 것 같아요

## 활동 សកម្មភាព

**작업하는 방법을 모르면 어떻게 말해야 돼요? 〈보기〉처럼 물어보세요.**

ប្រសិនជាមិនដឹងពីរបៀបធ្វើការ តើត្រូវធ្វើដូចម្តេច? សូមសាកល្បងធ្វើការសាកសួរដូចទៅនឹង<ឧទាហរណ៍>។

보기



작동하다 ដំណើរការ

가: 이거 어떻게 작동하는지 알아요? 좀 가르쳐 주세요.
តើដឹងថាធ្វើឲ្យវាដំណើរការដូចម្តេចទេ? សូមជួយបង្រៀនបន្តិច។

나: 네, 보세요. 이렇게 하면 돼요.
បាទ/ចាស, សូមមើល។ ធ្វើដូច្នេះជាការស្រេច។

1) 

꽂다

2) 

걸다

3) 

자르다

4) 

상자를 접다

5) 

달다

6) 

조절하다

**정답**
1) 이거 어떻게 꽂는지 알아요? 좀 가르쳐 주세요.
2) 이거 어떻게 거는지 알아요? 좀 가르쳐 주세요.
3) 이거 어떻게 자르는지 알아요? 좀 가르쳐 주세요.
4) 이거 어떻게 접는지 알아요? 좀 가르쳐 주세요.
5) 이거 어떻게 다는지 알아요? 좀 가르쳐 주세요.
6) 이거 어떻게 조절하는지 알아요? 좀 가르쳐 주세요.

## 정보 ព័ត៌មាន

# 안전한 도구 및 기계 사용법

របៀបប្រើប្រាស់ឧបករណ៍និងម៉ាស៊ីនដោយសុវត្ថិភាព



수공구는 확실하게 잡고 작업물에 정확하게 장착 후 사용해야 합니다.

មុនពេលប្រើប្រាស់ឧបករណ៍ ដៃគឺត្រូវកាន់ឧបករណ៍និងដាក់ឧបករណ៍លើរបស់ដែលត្រូវធ្វើការឲ្យបានច្បាស់លាស់។



회전하는 기계를 사용할 때는 장갑을 착용한 채로 만져서는 안 됩니다.

នៅពេលប្រើប្រាស់ម៉ាស៊ីនដែលវិល មិនត្រូវប៉ះពាល់ម៉ាស៊ីនដោយពាក់ស្រោមដៃនោះទេ។



연마 작업을 할 때는 장갑을 벗고 저속으로 회전시키면서 맨손으로 작업해야 합니다.

នៅពេលធ្វើការប៉ូលា ត្រូវដោះស្រោមដៃហើយបង្វិលយឺតៗហើយត្រូវធ្វើដោយដៃទទេ។



선반 작업을 시작하기 전에 일정 시간 기계를 공회전시켜서 부품의 물림 상태를 확인해야 합니다.

មុនពេលធ្វើការងារក្រឡឹង ត្រូវបង្វិលម៉ាស៊ីនចោលហើយពិនិត្យស្ថានភាពនៃការខាំរបស់ម៉ាស៊ីន។

# EPS-TOPIK 듣기 វិញ្ញាសាស្តាប់ EPS-TOPIK

សំណួរទី១និងទី២ គឺជាការជ្រើសរើសចម្លើយដែលមានទំនាក់ទំនងទៅនឹងអ្វីដែលបានស្តាប់។
មុននឹងស្តាប់ សូមក្រឡេកមើលខ្លឹមសាររបស់សំណួរជាមុនសិន។

[1~2] 들은 것을 고르십시오. សូមជ្រើសរើសយកពាក្យដែលអ្នកបានស្តាប់លឺ។

Track 132

1. ① 접어요. ② 작아요. ③ 좁아요. ④ 저예요.

2. ① 내려요. ② 눌러요. ③ 올려요. ④ 붙여요.

សំណួរទី៣និងទី៤គឺជាការស្តាប់សំណួរ បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ
ចំណែកឯសំណួរទី៥វិញ គឺជាការស្តាប់ការសន្ទនា បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។
មុននឹងស្តាប់ សូមក្រឡេកមើលខ្លឹមសារសំណួរជាមុនសិន។

[3~4] 질문을 듣고 알맞은 대답을 고르십시오. សូមស្តាប់សំណួរ បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

3. ① 아니요, 잘 쓸 수 있어요. ② 네, 전에도 사용해 봤어요.
③ 네, 주임님한테 물어볼게요. ④ 아니요, 기계가 여기 없어요.

4. ① 4시면 끝날 것 같아요. ② 이제 골판지를 오리세요.
③ 빨리 주문을 해야겠어요. ④ 상자는 이쪽에 쌓아 두세요.

5. 이야기를 듣고 질문에 알맞은 대답을 고르십시오.
សូមស្តាប់ការនិយាយ បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

남자가 해야 하는 일은 무엇입니까? តើការងារអ្វីដែលបុរសត្រូវធ្វើនៅថ្ងៃនេះ?

① 기계를 고쳐야 합니다. ② 기계를 옮겨야 합니다.
③ 기계로 작업해야 합니다. ④ 기계 사용법을 가르쳐야 합니다.



## 듣기 대본 អត្ថបទនៅក្នុងវិញ្ញាសាស្ដាប់

1. 남: 지금 상자를 접고 있지요? នៅពេលនេះកំពុងតែបត់កេសមែនទេ?
   여: 네, 지금 작업 중이에요. ចាស, ពេលនេះកំពុងតែធ្វើ។
2. 여: 어떻게 하면 작동해요? តើធ្វើដូចម្ដេចទើបវាដំណើរការ?
   남: 여기를 누르면 돼요. ចុចនៅកន្លែងនេះទៅជាការស្រេច។
3. 여: 이 기계 어떻게 사용하는지 알아요? តើដឹងថាម៉ាស៊ីននេះប្រើប្រាស់ដូចម្ដេចទេ?
4. 여: 상자 제작은 다 끝났어요? តើការផលិតកេសបានរួចរាល់ហើយឬនៅ?
5. 여: 여기가 다음 주부터 일하게 될 작업장이에요. 이건 리한 씨가 사용할 밴딩기고요. 어떻게 사용하는지 알지요?
   កន្លែងនេះជាកន្លែងដែលត្រូវធ្វើការចាប់ពីអាទិត្យក្រោយទៅ។ នេះជាម៉ាស៊ីនរុំដែលរីហាន់ត្រូវប្រើប្រាស់។ តើដឹងថាត្រូវប្រើប្រាស់ដូចម្ដេចទេ?
   남: 네, 어제 배웠습니다. 전에 다른 공장에서도 사용해 봤고요.
   បាទ, បានរៀនកាលពីម្សិលមិញរួចហើយ។ ហើយក៏ធ្លាប់ប្រើប្រាស់នៅរោងចក្រផ្សេងពីមុនមកដែរ។
   여: 그럼 잘하시겠네요. 먼저 여기 있는 안전 스위치를 내린 후에 사용하세요.
   អញ្ចឹងដឹងច្បាស់ហើយមើលទៅ។ មុនដំបូងសូមទម្លាក់កុងតាក់សុវត្ថិភាពហើយចាំប្រើប្រាស់។
   남: 네, 알겠습니다. បាទ, ខ្ញុំដឹងហើយ។

정답 1. ① 2. ② 3. ② 4. ① 5. ③

## 확장 연습 លំហាត់អនុវត្តបន្ថែម L-42

1. 대화를 듣고 질문에 알맞은 것을 고르십시오.
   សូមស្ដាប់ការសន្ទនា បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ។

   공장장이 늦게 온 이유는 무엇입니까? តើហេតុអ្វីបានជាប្រធានរោងចក្រមកយឺត?

   ① 용접기를 사지 못해서 ② 거래처에서 손님이 와서
   ③ 용접기에 문제가 생겨서 ④ 거래처 일이 늦게 끝나서

## 확장 연습 듣기 대본 អត្ថបទស្ដាប់នៅក្នុងលំហាត់អនុវត្តបន្ថែម

1. 남: 공장장님, 어서 오세요. 기다리고 있었어요. លោកស្រីប្រធាន, សូមស្វាគមន៍។ ខ្ញុំបានកំពុងតែរង់ចាំ។
   여: 미안해요. 거래처에서 일이 늦게 끝나서 늦었어요. 그런데 새로 들어온 용접기는 문제없어요?
   សូមទោស។ ដោយសារតែកន្លែងទំនាក់ទំនងអតិថិជនចប់ការងារយឺត ដូច្នេះហើយទើបបានជាមកយឺត។ ប៉ុន្តែម៉ាស៊ីនផ្សារដែលយកមកថ្មីគ្មានបញ្ហាទេឬ?
   남: 네, 전에 쓰던 것보다 간편하고 아주 좋아요. បាទ, វាងាយស្រួលប្រើប្រាស់ជាងម៉ាស៊ីនពីមុននិងពិតជាល្អណាស់។
   여: 잘됐네요. 그래도 위험하니까 사용할 때 조심하세요.
   ល្អហើយអញ្ចឹង។ ទោះបីជាយ៉ាងណាក៏ដោយ វាមានគ្រោះថ្នាក់ ដូច្នេះពេលប្រើប្រាស់សូមប្រុងប្រយ័ត្ន។

정답 1. ④

# EPS-TOPIK 읽기 វិញ្ញាសាអាន EPS-TOPIK

សំណួរទី១និងទី២គឺជាការមើលរូបភាព បន្ទាប់មកចូរជ្រើសរើសយកកន្សោមពាក្យដែលត្រឹមត្រូវ។
សូមរំលឹកពាក្យដែលបានរៀននៅខាងលើបណ្ដើរ បន្ទាប់មកចូរសាកល្បងឆ្លើយសំណួរបណ្ដើរ។

**[1~2] 다음 그림을 보고 맞는 문장을 고르십시오.**
សូមមើលរូបភាពខាងក្រោម បន្ទាប់មកចូរជ្រើសរើសយកប្រយោគដែលត្រឹមត្រូវ។

1.



① 목재입니다. ② 상자입니다.
③ 철근입니다. ④ 전구입니다.

2.



① 전선을 걸고 있습니다. ② 버튼을 누르고 있습니다.
③ 스위치를 올리고 있습니다. ④ 손잡이를 돌리고 있습니다.

សំណួរទី៣និងទី៤ គឺជាការជ្រើសរើសយកចម្លើយដែលត្រឹមត្រូវដើម្បីបំពេញចន្លោះ។
ចំណែកឯសំណួរទី៥វិញ គឺជាការអានអត្ថបទបន្ទាប់មកចូរឆ្លើយនឹងសំណួរ។

**[3~4] 빈칸에 들어갈 가장 알맞은 것을 고르십시오.** សូមជ្រើសរើសយកចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

3. 기계를 다 사용한 후에는 반드시 전원 스위치를 ________ 합니다.
បន្ទាប់ពីប្រើប្រាស់ម៉ាស៊ីនរួច ត្រូវតែទម្លាក់កុងតាក់ចុះ។

① 넣어야 ② 내려야 ③ 꽂아야 ④ 작동해야

4. 칼로 종이를 ________ 때는 손을 다치지 않게 조심해야 합니다.
នៅពេលកាត់ក្រដាសដោយកាំបិត ត្រូវតែប្រុងប្រយ័ត្នកុំឲ្យមានរបួសដៃ។

① 잴 ② 붙일 ③ 자를 ④ 접을

**5. 다음 질문에 답하십시오.** សូមឆ្លើយនឹងសំណួរខាងក្រោម។

민수 씨는 냄비를 만드는 곳에서 일을 합니다. 그런데 민수 씨는 이 일을 시작한 지가 얼마 안 됐기 때문에 기계를 어떻게 작동하는지 모릅니다. 그래서 주로 물건을 옮기는 일을 하고 있습니다. 그렇지만 곧 기계를 작동하는 방법을 배워서 냄비 만드는 일을 할 겁니다.

មីនស៊ូធ្វើការនៅកន្លែងផលិតឆ្នាំង។ ប៉ុន្តែដោយសារតែមីនស៊ូចាប់ផ្ដើមធ្វើការមិនទាន់បានប៉ុន្មាន ដូច្នេះគាត់មិនដឹងថាត្រូវដំណើរការម៉ាស៊ីនដូចម្ដេចនោះទេ។ ដូចនេះហើយភាគច្រើនគាត់កំពុងតែធ្វើការលើកទំនិញ។ ប៉ុន្តែមិនយូរប៉ុន្មានទៀតទេគាត់នឹងរៀនពីរបៀបដំណើរការម៉ាស៊ីន ហើយនឹងធ្វើការផលិតឆ្នាំង។

민수 씨는 지금 무슨 일을 합니까? តើមីនស៊ូកំពុងតែធ្វើការងារអ្វី?

① 냄비를 팝니다. ② 물건을 옮깁니다.
③ 냄비를 만듭니다. ④ 기계를 작동합니다.

정답 1. ② 2. ② 3. ② 4. ③ 5. ②



## 확장 연습 លំហាត់អនុវត្តបន្ថែម

[1~3] 빈칸에 들어갈 가장 알맞은 것을 고르십시오. សូមជ្រើសរើសយកចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

1.

오늘 오후에 안전 교육이 있습니다. 한 사람도 빠짐없이 ________ 직원들이 참석해야 합니다.

នៅរសៀលថ្ងៃនេះ គឺមានការបង្រៀនស្ដីពីសុវត្ថិភាព។ បុគ្គលិកទាំងអស់ត្រូវតែចូលរួមទាំងអស់គ្នាដោយមិនឲ្យបាត់សូម្បីតែម្នាក់។

① 벌써　② 방금
③ 어떤　④ 모든

2.

작업이 끝난 후에는 작업장을 잘 정리해야 합니다. 작업장을 항상 깨끗하게 ________ 사고를 줄일 수 있습니다.

ក្រោយពេលធ្វើការរួចហើយ ត្រូវតែរៀបចំកន្លែងធ្វើការឲ្យបានល្អ។ ទាល់តែរៀបចំកន្លែងធ្វើការឲ្យបានស្អាតជានិច្ចទើបអាចកាត់បន្ថយគ្រោះថ្នាក់បាន។

① 지어야　② 옮겨야
③ 치워야　④ 찾아야

3.

저는 새로 들여온 기계를 어떻게 ____________. 손잡이를 오른쪽으로 돌리고 빨간색 버튼을 누르면 됩니다.

ម៉ាស៊ីនដែលទើបតែយកមកថ្មីខ្ញុំដឹងថាត្រូវប្រើយ៉ាងម៉េច។ គ្រាន់តែបង្វិលប្រដាប់កាន់ទៅខាងស្ដាំ ហើយចុចប៊ូតុងពណ៌ក្រហមជាការស្រេច។

① 사용하고 싶습니다　② 판매하고 싶습니다
③ 사용하는지 압니다　④ 판매하는지 압니다

정답 1. ④ 2. ③ 3. ③

## 발음 ការបញ្ចេញសម្លេង

P-21

### សូមស្ដាប់ដោយយកចិត្តទុកដាក់រួចថាតាម

ក្នុងភាសាកូរ៉េ នៅពេលដែលមានព្យញ្ជនៈ២មកទន្ទឹមគ្នា វានឹងមានការប្រែប្រួលក្នុងការបញ្ចេញសម្លេងច្រើនបែបច្រើនសណ្ឋានណាស់។ នៅពេលព្យញ្ជនៈដែលប្រើសម្លេងបំពង់ក ទៅជួបនឹង ព្យញ្ជនៈសម្លេង‘ㄹ’, ពេលនោះត្រូវប្ដូរព្យញ្ជនៈទាំង២នេះ ទៅជាព្យញ្ជនៈដែលប្រើសម្លេងច្រមុះវិញ។ ប៉ុន្តែទីតាំងរបស់ព្យញ្ជនៈដើម គឺមិនមានការផ្លាស់ប្ដូរនោះឡើយ។

(1) 국립, 격려, 독립　(2) 압력, 협력, 격리
(3) 서로 협력해야 해요.　(4) 내일이 독립 기념일이에요.